# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## ឯកសារណែនាំសំរាប់មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសំភាសន៍

## ការអង្កេតមនុស្សមាត្រ កម្ពុជា ឆ្នាំ ២០០៨

ក្រសួងផែនការ
វិទ្យាស្ថានជាតិស្ថិតិ

ឧបបត្ថម្ភដោយ យូនីសេហ្វ និង យូអេនឌីភី
តុលា ឆ្នាំ ២០០៨

# ឧបសម្ព័ន្ធ១

# ឯកសារណែនាំសំរាប់មន្ត្រីសំភាសន៍

## I. **តួនាទីរបស់មន្ត្រីត្រួតពិនិត្យ**

មន្ត្រីត្រួតពិនិត្យនីមួយៗទទួលខុសត្រូវក្រុមសំភាសន៍របស់ខ្លួន។ ក្នុងក្រុមនីមួយៗនឹងត្រូវប្រមូលទិន្នន័យរួមមាន ការវាស់កំពស់ ការថ្លឹងទំងន់ និងការវាស់ដើមដៃ នៃស្ត្រីនិងកុមារ ។ មន្ត្រីត្រួតពិនិត្យទទួលខុសត្រូវ :

-ពិនិត្យមើល ( Oversee ) ការងាររបស់ក្រុម

-បែងចែកគ្រួសារឱ្យមន្ត្រីសំភាសន៍

-ជួយមន្ត្រីសំភាសន៍រកមើលផ្ទះ

-ចុះសួរឆ្នក់(Spot-cheek) អាស័យដ្ឋានមួយចំនួន ដែលបានជ្រើសរើសសំភាសន៍ ដើម្បីធានាឱ្យបានថា មន្ត្រីសំភាសន៍ពិតជាបានសំភាសន៍ចំគ្រួសារដែលបានជ្រើសរើស ( Correct household ) ។

-ពិនត្យឡើងវិញរាល់អ្វីដែល មន្ត្រីសំភាសន៍មិនបានសំភាសន៍

-សង្កេតមើលការសំភាសន៍របស់មន្ត្រីសំភាសន៍ ដើម្បីធានាថា មន្ត្រីសំភាសន៍បានសួរសំណួរតាមបែបបទត្រឹមត្រូវ ហើយកត់ត្រាចំលើយត្រឹមត្រូវ។

-គ្រប់គ្រងថវិកានិងសំភារៈ។

-ត្រួតពិនិត្យការវាស់-ថ្លឹង ។

-ជួបជាមួយមន្ត្រីសំភាសន៍រៀងរាល់ថ្ងៃ ដើម្បីពិភាក្សាអំពីការអនុវត្ត និងការបែងចែកការងារសំរាប់ថ្ងៃបន្ទបន្ទាប់ ។

-ជួយមន្ត្រីសំភាសន៍ក្នុងការរកមើលផ្ទះ ( គ្រួសារ )ដែលត្រូវសំភាសន៍ឬ ពន្យល់តារាងសំណួរ ឬដោះស្រាយជាមួយអ្នកឆ្លើយតបដែលពិបាក ។

- ឆែកពិនិត្យ និងកែតារាងសំនួរបំពេញរួច របស់មន្ត្រីសំភាសន៍រាល់ថ្ងៃ។

## II. **តួនាទីរបស់មន្ត្រីសំភាសន៍**

មន្ត្រីសំភាសន៍ត្រូវប្រកាន់ខ្ជាប់ នូវតួនាទីកណ្តាលនៅក្នុង អង្កេតមនុស្សមាត្រកម្ពុជា ( អ,ម.ក) ដោយសារតែពួកគេប្រមូល ពិតមានពីអ្នកឆ្លើយតប។ ហេតុដូច្នេះហើយជោគជ័យនៃ អ,ម,ក អាស្រ័យ

ទៅលើគុណភាព នៃការងាររបស់មន្ត្រីសំភាសន៍ម្នាក់ៗ ។ ជាទូទៅការទទួលខុសត្រូវ នៃមន្ត្រីសំភាសន៍ម្នាក់ៗ គឺមានដូចតទៅ :

-ពិនិត្យមើលរចនាសម្ព័ន្ធ និងគ្រួសារនៅក្នុងការជ្រើសរើសគំរូ ហើយបំពេញតារាងសំនួរគ្រួសារ

-កំនត់រាល់ស្ត្រីដែលអាចជ្រើសរើសសំរាប់ធ្វើការសំភាសន៍នៃ អ.ម.ក

-ពិនិត្យមើលការសំភាសន៍ដែលបានបំពេញហើយ ដើម្បីធានាឱ្យបានថា រាល់សំណួរទាំងអស់ត្រូវបានសួរ ហើយរាល់ការឆ្លើយត្រូវកត់ត្រាឱ្យបានត្រឹមត្រូវ និងមានរបៀប(really and legibly)

-វាស់ ថ្លឹង និងកត់ត្រាកំពស់និងទំងន់ស្ត្រីនិងកុមារ

## III. ការបំពេញតារាងសំនួរ

***បង្គោល(១០១):*** *សមាជិកគ្រួសារ និងភ្ញៀវ*

ជំហ៊ានដំបូងក្នុងការបំពេញផ្នែកទី១នៃតារាងសំនួរ ត្រូវចុះបញ្ជីស្ត្រីទាំងអស់ដែលកំពុងរស់នៅជាប្រក្រតីក្នុងគ្រួសារ ហើយដែលមានកូនអាយុក្រោម៥ឆ្នាំ។ ដើម្បីទទួលបានបញ្ជីត្រឹមត្រូវ អ្នកត្រូវយល់ឱ្យច្បាស់ អ្វីទៅជាសមាជិកគ្រួសារ ហើយអ្វីទៅជាភ្ញៀវ។

*សមាជិកនៃគ្រួសារ:* គ្រួសារមួយអាចជាមនុស្សម្នាក់ឬមនុស្សច្រើននាក់រស់នៅជាប្រក្រតី ហើយបរិភោគរួមគ្នា។ ដូច្នេះវាខុសពីពាក្យថាគ្រួសារផ្ទាល់ (family)។ គ្រួសារផ្ទាល់រួមមានម្នាក់ដែលជាសាច់ញ្ញិត ប៉ុន្តែគ្រួសាររួមបញ្ចូលមនុស្សណាដែលរស់នៅជាមួយគ្នាទោះបីថាសាច់ញ្ញាតិឬ មិនសាច់ញ្ញាតិក៏ដោយ។ ឧទាហរណ៏ បុរសបីនាក់ មិនមែនជាសាច់ញ្ញាតិនឹងគ្នា ហើយរស់នៅចំអិនអាហារជាមួយគ្នា មិនអាចចាត់ទុកថាជាគ្រួសារផ្ទាល់ទេ ប៉ុន្តែពួកគេអាចចាត់ទុកថាជា សមាជិកនៃគ្រួសារ។

*ភ្ញៀវ:* ជាអ្នកដែលមិនមែនជាសមាជិកប្រក្រតីនៃគ្រួសារ ប៉ុន្តែបានស្នាក់នៅក្នុងគ្រួសារនេះកាលពីយប់មិុលមិញ មុនពេលអ្នកធ្វើការសំភាសន៍។ បើមានបុគ្គលណាម្នាក់ស្នាក់នៅក្នុងគ្រួសារ កាលពីយប់មិុលមិញ បុរស ឬស្ត្រីត្រូវបានចុះបញ្ជីរនៅក្នុងសំនួរគ្រួសារ។

ពេលខ្លះ វាមិនមែនជាការងាយស្រួលទេដើម្បីស្គាល់ថានរណាជាគ្រួសារ ហើយនរណាមិនមែនជាសមាជិកគ្រួសារ។ សូមមើលឧទាហរណ៏ខាងក្រោម:

-ស្ត្រីម្នាក់ចុះបញ្ជីប្តីគាត់ជាមេគ្រួសារ ប៉ុន្តែគាត់រស់នៅកន្លែងផ្សេង។ បើគាត់មិនស្នាក់នៅជាប្រក្រតីក្នុងគ្រួសារដែលអ្នកកំពុងសំភាសន៏ទេ។ ហើយមិនបានគេងនៅក្នុងគ្រួសារនេះទេ កាលពីយប់មិុលមិញគាត់មិនត្រូវបានបញ្ចូលក្នុងបញ្ជីទេ។

-ពេលខ្លះ គេបរិភោគនៅក្នុងគ្រួសារតែមួយ ប៉ុន្តែស្នាក់នៅក្នុងគ្រួសារផ្សេងៗ។ ចូរចាត់បុគ្គលនោះជាសមាជិកនៃគ្រួសារដែលបានស្នាក់នៅ (ដេកនៅទីនោះ) ។

-បុគ្គលម្នាក់រស់នៅម្នាក់ឯងគឺជាគ្រួសារ។

-អ្នកបំរើគឺជាសមាជិកនៃគ្រួសារ បើស្ត្រីឬ បុរសនោះរស់នៅជាប្រក្រតីនៅក្នុងគ្រួសារនោះ។

អ្នកណាម្នាក់ ដែលបញ្ចូលក្នុងបញ្ជីម្តាយ អោយតែអ្នកនោះរស់នៅ ជាប្រក្រតីក្នុងគ្រួសារនោះ ហើយបានគេងនៅក្នុងគ្រួសារនោះពីយប់ម្សិលមិញ។

នៅពេលដែលអ្នកឆ្លើយរាយឈ្មោះ ចូរកត់ឈ្មោះនៅក្នុងជួរនិមួយៗនៃបង្គោល(១០១)នៃតារាង។ បុគ្គលដែលត្រូវបានកំណត់ថាជាមេគ្រួសារគឺជាអ្នកដែលបានរស់នៅជា ប្រក្រតីក្នុងគ្រួសារនោះ។ បុគ្គលនេះ អាចចាត់ទុកជាមេគ្រួសារ គឺដោយផ្អែកលើអាយុ(ចាស់ជាង) ភេទ(ជាទូទៅជាបុរស ប៉ុន្តែមិនចាំបាច់ទេ) ។ ស្ថានភាពសេដ្ឋកិច្ច ឬមូលហេតុផ្សេងទៀត។ វាស្រេចតែ អ្នកឆ្លើយតបដែលកំណត់ថាអ្នកណាជាមេគ្រួសារ។ ជាទូទៅវាមិនមានបញ្ហាទេរឿងនេះ។

***<u>បង្គោល(១០២)</u>:*** *ទំនាក់ទំនងគ្រួសារ*

កត់ត្រាមនុស្សដែលបានរាយឈ្មោះ ដែលមានទំនាក់ទំនងទៅនឹងមេគ្រួសារ ដោយចុះលេខកូដនៅផ្នែកខាងក្រោមនៃទំព័រ។ បើអ្នកឆ្លើយតបមិនមែនជាមេគ្រួសារ ត្រូវច្បាស់ថាអ្នកត្រូវកត់ត្រាទំនាក់ទំនងនៃបុគ្គលម្នាក់ៗទៅនិងមេគ្រួសារ មិនមែនទំនាក់ទំនងជាមួយអ្នកឆ្លើយតបទេ។

ឧទាហរណ៏: បើអ្នកឆ្លើយតបជាប្រពន្ធរបស់មេគ្រួសារហើយគាត់និយាយថា ចន្ថាគឺជាបងប្រុសគាត់ដូច្នេះចន្ថាត្រូវដាក់កូដជាញាតិសន្តានផ្សេងទៀត មិនមែនបងប្រុសឬបងស្រីទេពីព្រោះ ចន្ថាគឺជាបងថ្លៃរបស់មេគ្រួសារ។បើមេគ្រួសាររៀបការជាមួយស្ត្រីដែលមានកូនជាមួយប្តីមុនដូច្នេះទំនាក់ទំនងកូននោះជាមួយមេគ្រួសារគឺកូដ ៥ (កូនចិញ្ចឹម ,កូនចុង) ។

***<u>បង្គោល(១០៣)</u>:*** *អាយុ*

បើអ្នកមានការលំបាកក្នុងការទទួលយកអាយុសមាជិកគ្រួសារចូរប្រើវិធីដែលបានពិពណ៌នាក្នុងសំណួរ 216 និង 217 ក្នុងតារាងសំណួរស្ត្រីដើម្បីសួរយោងរកអាយុត្រឹមត្រូវ។ អ្នកត្រូវតែបានអាយុបុគ្គលម្នាក់ៗជា <u>ឆ្នាំពេញលេញ</u>។ នោះគឺអាយុនៅពេលថ្ងៃកំណើតចុងក្រោយ។

***បង្គោល (១០៤-១០៦): ការថ្លឹងទំងន់ ការវាស់កំពស់ និង ការវាស់ដើមដៃ***

ការថ្លឹងទំងន់ ការវាស់កំពស់ និង ការវាស់ដើមដៃ ត្រូវអនុវត្តន៍បន្ទាប់ពីបញ្ចប់ការសំភាសន៍ទាំងពីផ្នែក( ផ្នែកទីមួយ និងផ្នែកទីពីរ) ដោយអនុវត្តទៅតាមការណែនាំផ្នែកមនុស្សមាត្រនៃឯកសារណែនាំនេះ ។

a) កត់ត្រាទំងន់ស្ត្រី ជាគីឡូក្រាម

b) កត់ត្រាកំពស់ស្ត្រី ជាសង់ទីម៉ែត្រ

c) កត់ត្រាដើមដៃស្ត្រី ជាសង់ទីម៉ែត្រ

**សំនួរ ១០៧:** សំភារៈរបស់របរគ្រួសារ

ចំលើយចំពោះសំណួរទាំងនេះអំពីកម្មសិទ្ធិ នៃរបស់របរនានា នឹងត្រូវប្រើសំរាប់វាស់ស្ថានភាពសេដ្ឋកិច្ចសង្គម ។ ចូរអានរបស់ នីមួយៗ ហើយគូសរង្វង់ចំលើយដែលបានឱ្យដោយមិនត្រូវទុកផ្នែកណាមួយទំនេរទេ ។

បើសិនអ្នកឆ្លើយតបរាយការណ៍ថា របស់របរគ្រួសារដូចជា វិទ្យុ ខូចហើយ ចូរព្យាយាមសួរថាវាខូចអស់រយៈពេលប៉ុន្មានខែ/ឆ្នាំហើយ ហើយថាតើវាមានបានជួសជុលឬទេ? បើសិនថារបស់របរនោះគ្រាន់តែឈប់ប្រើប្រាស់បណ្តោះអាសន្ន ចូរគូសរង្វង់ (១) "ចាស់ " ។បើមិនដូច្នេះទេ គូសរង្វង់(២)ចំលើយទេ។

***សំនួរ ១០៨: សំភារៈដំបូល***

អ្នកមិនចាំបាច់សួរអ្នកឆ្លើយតបអំពីសំភារៈដំបូលទេ ដោយអ្នកអាចរកមើលឃើញដោយផ្ទាល់នូវប្រភេទសំភារៈដំបូល ។ ប៉ុន្តែសង្កេតមើលសំភារៈដំបូលជាទូទៅមិនងាយស្រួលទេ ឬមួយអ្នកអាចសង្កេតមើលផ្នែកណាមួយ ប៉ុន្តែមិនមែនទាំងស្រុងទេ។ ចូរសួរអ្នកឆ្លើយតប បើអ្នកមិនច្បាស់ឬបើអ្នកមិនអាចសង្កេតមើលដំបូលបានល្អ។ បើគ្រួសាររស់នៅក្នុងអាគារផ្ទះល្វែង ចូរមើលដំបូលពីចំងាយសមស្របហើយសួរបើចាំបាច់ ។ បើមានសំភារៈដំបូលលើសពី១ប្រភេទ ចូរកត់ត្រាប្រភេទចំបងគេនៃដំបូល ។

***សំនួរ ១០៩: កម្មសិទ្ធនៃមធ្យោបាយធ្វើដំណើរ***

ក៏ដូចជារង្វាស់នៃស្ថានភាពសេដ្ឋកិច្ចសង្គម យើងក៏សួរថាតើសមាជិកណាមួយនៃគ្រួសារមាន កង់ម៉ូតូ រថយន្ត និងរបស់របរ ផ្សេងទៀត ។ ចូរធ្វើដូចគ្នាក្នុងសំណួរ ១០៧ ក្នុងការសួររបស់របរទាំងនោះ ។ កូនកង់សំរាប់កូនក្មេងគឺជារបស់ក្មេងលេងមិនរាប់បញ្ចូល ក្នុងនេះទេ ។

***សំនួរ ១១០ និង ១១១:*** *កម្មសិទ្ធនៃដីធ្វើស្រែចំការ*

កម្មសិទ្ធដីធ្វើស្រែចំការ គឺជាអាំងឌីកាទ័រសំខាន់មួយទៀតនៃ ស្ថានភាពសេដ្ឋកិច្ចសង្គមរបស់គ្រួសារ។ ដំបូងចូរសួរសំនួរ១១០ ដើម្បីរកមើលថាតើសមាជិកគ្រួសារណាម្នាក់មានកម្មសិទ្ធដីដែលអាចប្រើសំរាប់ធ្វើស្រែចំការ ។ បើចំលើយ "ចាស់" សួរសំនួរ ១១១ អំពីចំនួនម៉ែត្រការ៉េ ដែលជាកម្មសិទ្ធទាំងអស់គ្នានៃសមាជិកគ្រួសារ។ កត់ត្រាចំលើយក្នុងប្រអប់។

*សំគាល់* ១ ហិកតា= ១០០ អា = ១០០០០ ម៉ែត្រការ៉េ

១រ៉ៃ = ១៦អា = ១៦០០ ម៉ែត្រការ៉េ

***សំនួរ ១១២ និង ១១៣:*** *កម្មសិទ្ធនៃសត្វពាហនៈ បក្សីស្រុក ឬសត្វពាហនៈផ្សេងៗទៀត*

ពត៌មានអំពីថាតើគ្រួសារមានកម្មសិទ្ធសត្វពាហនៈ បក្សីស្រុក ឬសត្វពាហនៈផ្សេងទៀត ហើយមានចំនួនប៉ុន្មានត្រូវបានប្រើជាអាំងឌីកាទ័របន្ថែម សំរាប់ស្ថានភាពសេដ្ឋកិច្ចសង្គមនៃគ្រួសារ។ ដំបូងចូរសួរ សំនួរ ១១២ ដើម្បីរកមើលថាតើគ្រួសារមានកម្មសិទ្ធ សត្វពាហនៈ សត្វចំការជាដើម ។ បើចំលើយ "ចាស់ " ចូរអ្នកសួរសំនួរ ១១៣ ដើម្បីរកមើលប្រភេទសត្វពាហនៈដែលគ្រួសារកម្មសិទ្ធ ហើយមានសត្វមួយៗចំនួនប៉ុន្មានក្បាល។ ចូរអានសំណួរនីមួយៗហើយត្រូវច្បាស់ថា កត់ត្រាចំនួននៅក្នុងប្រអប់នីមួយៗ មិនត្រូវទុកប្រអប់នេះឱ្យនៅទំនេរទេ ។

***សំនួរ ១១៤-១១៦:*** *អនុវត្តទៅតាមសេចក្តីណែនាំក្នុងតារាងសំនួរ។*

***សំនួរ ១១៧:*** អនុញ្ញាតិឱ្យអ្នកឆ្លើយធ្វើការសំរេចចិត្តជ្រើសរើសចំលើយ (រៀងរាល់ថ្ងៃ ញឹកញាប់ ម្តងម្កាល កម្រមាន មិនដែលសោះ) ។ ប្រសិនបើអ្នកឆ្លើយសួររកការបញ្ជាក់បន្ថែម អ្នកសំភាសន៍ត្រូវធ្វើការ ពន្យល់បន្ថែម។

***សំនួរ ១១៨:*** *ប្រភេទអំបិល*

គោលបំណងនៃសំនួរនេះគឺដើម្បីបានស្មានថាតើ គ្រួសារប្រើអំបិលដែលមានជាតិអ៊ីយ៉ូដសំរាប់ចំអិនអាហារ ។ អំបិលមានជាតិអ៊ីយ៉ូដ អាចការពារកង្វះខាតអ៊ីយ៉ូដបាន ។ ជាតិអ៊ីយ៉ូដជាមីក្រូសារធាតុសំខាន់ ហើយសារធាតុនេះអាចបណ្តាលអោយក្រពេញទីរ៉ូអ៊ីដ រីកធំត្រង់ក ដែលគេស្គាល់វាថា ជំងឺពកក។ ចូរសុំអំបិលសំរាប់ស្ទួបន្ថិច ពីអ្នកឆ្លើយតប (បរិមាណប្រហែលកន្លះស្លាប់ព្រាកាហ្វេ) ។ បើអ្នកឆ្លើយតបប្រើអំបិលលើសពីមួយប្រភេទ ចូរច្បាស់ថាអំបិលដែលគាត់អោយ ជាអំបិលដែលគ្រួសារប្រើសំរាប់ដាំស្ល។ ដើម្បីពិសោធន៏មើល សមាសធាតុអ៊ីយ៉ូដ ដំបូងក្រឡេកមើលដបដែលមានទឹកវាវថ្លា ហើយ

ច្របាច់យក មួយដំណក់ដាក់ចំកណ្តាលអំបិលដែលពិសោធន៍មើល ។ បើអំបិលមានសារធាតុអ៊ីយ៉ូដវានិងប្តូរពណ៌ ។ ចូរប្រៀបធៀបពណ៌អំបិលជាមួយគំរូពណ៌នៅផ្នែកខាង នៃជាតិអ៊ីយ៉ូដ ។ ចូរកត់ត្រាថាតើអំបិលមានជាតិ អ៊ីយ៉ូដ ឬអត់ ? ។

បើគ្មានប្រែពណ៌ទេ អ្នកត្រូវធ្វើពិសោធន៍ជាលើកទី២ ដោយសុំអំបិលថ្មីទៀត ។ ដំបូងចូរពង្រាបអំបិល ដើម្បីឱ្យវារាបស្មើមិន កំពិតកំពក បន្ទាប់មកក្រឡុងដបមានសារធាតុរាវពណ៌ស៊ីជំពូ ហើយច្របាច់យកមួយដំណក់ ចំកណ្តាលអំបិល ។ បន្ទាប់មកច្របាច់យក មួយដំណក់សារធាតុរាវថ្លាចំពីលើកន្លែងបន្តក់ពីមុន ។ ចុងបញ្ចប់ប្រៀបធៀបពណ៌អំបិល ជាមួយគំរូរពណ៌នៅលើជាតិអ៊ីយ៉ូដហើយកត់ត្រាលទ្ធផល ។ បើនៅតែមានពណ៌ស ដដែល ចូរកត់ត្រា គ្មានអ៊ីយ៉ូដ ។ បើពណ៌ផ្លាស់ប្តូរកត់ត្រាមានអ៊ីយ៉ូដ ។

***សំនួរ ២០១-២១៥:*** *បញ្ជីឈ្មោះកុមារ*

បន្ទាប់ពីបញ្ចប់ផ្នែកទី១ ម្តាយរបស់កុមារដែលមានអាយុក្រោម៥ឆ្នាំ ត្រូវសំភាសន៍ដាច់ដោយឡែកពីគ្នាសំរាប់ផ្នែកទី២ ។ សំរាប់ម្តាយដែលរស់នៅជាមួយកុមារអាយុក្រោម៥ឆ្នាំ ត្រូវកត់ត្រាកូនទាំងអស់ដែលកើតក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ។

ករណីកុមារអាយុក្រោម៥ឆ្នាំ ដែលគ្មានវត្តមានម្តាយ បំពេញតែសំនួរពីបញ្ជីកុមារ ដោយអនុវត្តទៅតាមការណែនាំដែលមាននៅក្នុងបន្ទាត់លេខ ២០១ ។

***បន្ទាត់លេខ ២០១:*** *លេខរៀងម្តាយ/អ្នកថែទាំ*

បំពេញលេខរៀងម្តាយ/អ្នកថែទាំពីបង្គោល ១០១ ក្នុងប្រអប់ដែលបានផ្តល់ឱ្យ ។ បើសិនជាមានកុមារអាយុក្រោម ៥ឆ្នាំ ដែលម្តាយស្លាប់ចោល ឬមិនរស់នៅជាមួយ ចូរបំពេញលេខកូដសមស្រប (97 ឬ 98 ) ក្នុងប្រអប់ដែលបានផ្តល់ឱ្យ ។ បន្ទាប់មកចុះបញ្ជីកុមារ ហើយបំពេញសំនួរនៅផ្នែកខាងលើនៃទំព័រ ដោយមានការជួយឆ្លើយពីអ្នកថែទាំកុមារ ។ បន្ទាប់ពីបញ្ចប់ ការបំពេញសំនួរនៅផ្នែកខាងលើនៃទំព័ររួចមក ការសំភាសន៍ត្រូវបញ្ចប់ ដោយសារតែផ្នែកបន្ទាប់នៃតារាងសំនួរ សំរាប់តែម្តាយរបស់កូនតែប៉ុណ្ណោះ ។

***សំនួរ ២០២:*** *ឈ្មោះកុមារ*

*ចំពោះម្តាយ:* ចូរកត់ត្រាឈ្មោះកូនទាំងអស់ដែលកើតក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ។

*ចំពោះអ្នកថែទាំ:* ចូរកត់ត្រាឈ្មោះកុមារអាយុក្រោម៥ឆ្នាំទាំងអស់ដែលរស់នៅក្នុងគ្រួសារ ។

***សំនួរ ២០៣:*** *កំណើតម្តងមួយ ឬកំណើតច្រើន ( ភ្លោះ )*

សំរាប់កូនភ្លោះ កូនម្តងបី ឬ កើតម្តងលើសពីមួយ សូមកត់ត្រា "ច្រើននាក់" ។

***សំនួរ ២០៤:*** *ភេទរបស់កូន*

ទោះបីថាអ្នកអាចដឹងភេទរបស់កូនពីឈ្មោះ ចូរផ្ទៀងផ្ទាត់ជាមួយអ្នកឆ្លើយតប ដោយនិយាយថា តើ ចិន្តា ជាក្មេងប្រុស ឬ? មិន ត្រូវសន្មត់ភេទរបស់កុមារតាមឈ្មោះឡើយ ។

***សំនួរ ២០៥:*** *ខែ និងឆ្នាំកំណើត*

១. បើសិនអ្នកឆ្លើយដឹង ខែ ឆ្នាំកំនើតក្មេង ជាខែ ឆ្នាំសកល ចូរកត់ត្រាខែនិងឆ្នាំក្នុងប្រអប់ ដែលបានផ្តល់អោយ ។

២. បើអ្នកឆ្លើយមិនដឹង ខែ ឆ្នាំកំណើតក្មេងជា ខែ ឆ្នាំសកល ចូរសួររក ខែ ឆ្នាំកំនើតជាខែ ឆ្នាំខ្មែរ ។ កត់ត្រា ខែ ឆ្នាំកំណើតក្មេងជា ខែ និង ឆ្នាំ នៅជាយខាងនៃតារាងសំនួរលើបន្ទាត់តែមួយ រួចធ្វើការបង្វែរ អាយុពី ខែ ឆ្នាំ ខ្មែរទៅជា ខែ និង ឆ្នាំសកល ដោយប្រើប្រាស់តារាងបង្វែរអាយុសំរាប់ក្មេង ក្រោមប្រាំឆ្នាំ និង តារាងបង្វែរអាយុផ្សេងទៀត ។

បើសិនអ្នកឆ្លើយផ្តល់ពតិមានតែឆ្នាំកំណើត តែមិនដឹងខែកំណើត ចូរព្យាយាមសួរយោង ដើម្បីប៉ាន់ស្មាន ខែកំណើត ។ ឧទាហរណ៍ បើអ្នកឆ្លើយប្រាប់ថាកូនស្រីគាត់ កើតក្នុងឆ្នាំ ១៩៨៧ តែគាត់ មិនបានប្រាប់ខែកំនើតរបស់ កូនស្រីគាត់ទេ, ចូរព្យាយាមសួរអ្នកឆ្លើយថាគាត់បានផ្តល់កំនើតនៅក្នុង រដូវប្រាំង ឬ រដូវវស្សា ឬក៏មុន ឬ ក្រោយ រដូវប្រមូលផលស្រូវ ដើម្បីកំនត់ខែកំនើត ។ ចូរបង្វែរខែ ខ្មែរទៅជាខែសកលដូចបានរៀបរាប់ខាងលើ ។

៣. បើអ្នកឆ្លើយមិនអាចនឹកឃើញឆ្នាំពេលដែលគាត់ឆ្លងទន្លេ មន្ត្រីសំភាសន៍ចាំបាច់ត្រូវប្រុង ប្រយ័ត្ន ដើម្បីផ្ទៀងផ្ទាត់ចំលើយជាមួយពតិមាន ដែលប្រមូលបាននៅពេលចាប់ផ្តើមនៃការចុះសំភាសន៍ ដូចជាសំបុត្រកំណើត លិខិតចាក់វ៉ាក់សាំង ដើម្បីផ្ទៀងផ្ទាត់ជាមួយថ្ងៃខែឆ្នាំកំនើត ។ ម្យ៉ាងទៀត មុនពេល កត់ត្រាថ្ងៃខែឆ្នាំ កំណើតចូលក្នុងតារាងសំនួរ ចូរព្យាយាមសួរអ្នកឆ្លើយ ដើម្បីបញ្ជាក់ថា ថ្ងៃខែឆ្នាំកំនើត នេះពិតជាត្រឹមត្រូវពិតប្រាកដ ។

បើសិនជាគ្មានសៀវភៅកត់ត្រាគ្រួសារ ឬ សំបុត្រកំណើត ដែលបញ្ជាក់ពតិមានអំពីក្មេង ចូរ ពិនិត្យមើល ថាតើអ្នកឆ្លើយ និង ការបរិច្ឆេទនៃកំណើតក្មេងណាមួយពិតប្រាកដ ដែលរស់នៅក្នុងគ្រួសារ ហើយភ្ជាប់សំនួរដដែល ដើម្បីសួររកអាយុក្មេងម្នាក់ទៀត ។ ឧទាហរណ៍ បើអ្នកឆ្លើយដឹងថាកូនទីពីររបស់ គាត់កើតនៅឆ្នាំ១៩៨៥ ហើយគាត់បញ្ជាក់ថា កូនទីមួយរបស់គាត់ មានអាយុចាស់ជាងកូនទីពីរ មួយឆ្នាំ

នោះអ្នកសំភាសន៍ត្រូវកត់ត្រាឆ្នាំកំណើត គឺ១៩៨៤ សំរាប់កូនទីមួយ ។ អ្នកសំភាសន៍ត្រូវកត់ត្រាឆ្នាំ និង ខែកំណើតរបស់ក្មេងទាំងអស់ ទោះបីឆ្នាំ និង ខែកំណើតជា ពតិមានប៉ាន់ស្មានក៏ដោយ ។

***សំនួរ ២០៦:*** *ស្ថានភាពមានជីវិតរស់នៅ*

គូសរង្វង់លេខកូដ ទោះបីជាក្មេងនៅរស់ ឬស្លាប់ក៏ដោយ ។ បើក្មេងស្លាប់ ចូររំលងទៅ សំនួរ២០៩ បើក្មេងនៅរស់, សួរសំនួរ ២០៧ ។

***សំនួរ ២០៧:*** *អាយុក្មេង*

សូមយកចិត្តទុកដាក់ចំពោះសំនួរនេះអាយុនិងថ្ងៃខែឆ្នាំកំណើតរបស់អាយុក្មេងម្នាក់ៗ ជាពតិមានសំខាន់បំផុតសំរាប់ការអង្កេតនេះ ។ ចំលើយត្រូវកត់ត្រាជាឆ្នាំពេញ ។ អាយុក្មេងដែលកំពុងរស់នៅទាំងអស់ត្រូវតែកត់ត្រាតាមប្រពន្ធ័ឆ្នាំសកល គឺមិនមែនជាឆ្នាំខ្មែរឡើយ ។ ប្រពន្ធ័ឆ្នាំសកល រាប់ចំនួនឆ្នាំពេញលេញ ចាប់ពីកាលបរិច្ឆេទនៃ កំណើតរបស់ក្មេង ។ ឧទាហរណ៍ ក្មេងម្នាក់នឹងមានអាយុបីឆ្នាំក្នុងថ្ងៃកំណើតរបស់គាត់នៅសប្តាហ៏ក្រោយ ។ ដូច្នេះក្មេង នេះត្រូវកត់ត្រាអាយុតែពីរឆ្នាំប៉ុណ្ណោះ នៅថ្ងៃនេះ ។ ចំពោះក្មេងអាយុតិចជាងមួយឆ្នាំត្រូវកត់ត្រា "00" ឆ្នាំ ។

ម្យ៉ាងទៀតពេលខ្លះម្តាយមិនដឹងអាយុកូនរបស់ខ្លួននាពេលបច្ចុប្បន្ននេះទេ ។ ក្នុងករណីនេះ អ្នកសំភាសន៍ អាចប្រើប្រាស់ពតិមានផ្សេងទៀត ដែលអាចទុកចិត្តបាន ដើម្បីគណនាអាយុនេះ ។ ឧទាហរណ៍ ដូចជាមន្ត្រីសំភាសន៍ អាចភ្ជាប់ទំនាក់ទំនងអាយុរបស់ចិន្តា ទៅនឹងអាយុក្មេងម្នាក់ទៀតដែលម្តាយរបស់គាត់បានដឹង ។ ម្យ៉ាងទៀតម្តាយរបស់ក្មេងអាចដឹងថា កូនពៅបង្អស់របស់គាត់បានកើតមួយឆ្នាំកន្លងមក ហើយចិន្តាមានអាយុ២ឆ្នាំ នៅពេលនោះ ដូច្នេះ ចិន្តា ត្រូវមានអាយុ៣ឆ្នាំនាពេលបច្ចុប្បន្ននេះ ។ មន្ត្រីសំភាសន៍ ត្រូវកត់ត្រាអាយុសំរាប់ក្មេងទាំងអស់ដែលកំពុងមានជីវិតរស់នៅ ។

*ការត្រួតពិនិត្យផ្សេងទៀត: ថ្ងៃ ខែ ឆ្នាំកំណើតនិងអាយុ*

មន្ត្រីសំភាសន៍មិនទាន់អាចបញ្ចប់ត្រឹមសំនួរ២០៧ បានទេ គឺត្រូវត្រួតពិនិត្យដើម្បីធ្វើការផ្ទៀងផ្ទាត់រវាងសំនួរ ២០៥ និង សំនួរ២០៧ ។ ចូរត្រួតពិនិត្យដើម្បីផ្ទៀងផ្ទាត់អាយុតាមការណែនាំពន្យល់សំរាប់សំនួរ១០៥ និង១០៦ ។ មន្ត្រីសំភាសន៍អាចធ្វើការផ្ទៀងផ្ទាត់តាមបែបគណនាគណិតវិទ្យា ឬ តាមតារាងត្រួតពិនិត្យអាយុកាលបរិច្ឆេទកំណើតបូកឆ្នាំកំណើតនិងអាយុ ។

បើក្មេងមានខួបកំណើតនៅក្នុងឆ្នាំនេះ តាមបែបគណិតវិទ្យា ឆ្នាំកំណើតមុនខែចុះសំភាសន៍ នោះផលបូកតាមគណិតវិទ្យាត្រូវស្មើ ២០០៨ បើក្មេងមិនទាន់មានខួបកំនើតក្នុងឆ្នាំនេះនៅឡើយ ឆ្នាំកំណើតក្រោយខែចុះសំភាសន៍ នោះផលបូកតាមគណិតវិទ្យាត្រូវស្មើ ២០០៧ ។ ម្យ៉ាងទៀតបើក្មេងមាន

ឆ្នាំកំណើតនៅខែចុះសំភាសន៍ ឬក៏មិនដឹងឆ្នាំកំណើតសោះ នោះផលបូកតាបគណិតវិទ្យាអាចឆ្នាំ ២០០៧ ឬ ២០០៨។

បើសិនជាឆ្នាំកំណើត និងអាយុមិនស៊ីគ្នា,សូមសួរយោងបន្ថែម ដើម្បីទទួលបានពតិមានពិតប្រាកដ។ សូមចងចាំថាពេលសួរសំនួរយោងត្រូវគិតថាមានសំនួរទាក់ទងនឹងអាយុ ឬ សំនួរទាក់ទងនឹងកាលបរិច្ឆេទកំណើតអាចផ្តល់ចំលើយមិនបានត្រឹមត្រូវ ឬក៏សំនួរទាំងពីរមិនអាចផ្តល់ចំលើយបានត្រឹមត្រូវក៏មានដែរ។

***សំនួរ២០៨:*** *ក្មេងដែលរស់នៅជាមួយម្តាយ*

សំនួរនេះមានសារៈសំខាន់ណាស់សំរាប់កំណើត រយៈពេលដែលក្មេងៗរស់នៅឆ្ងាយពីម្តាយខ្លួន បើក្មេងរស់នៅឆ្ងាយ នៅសាលាអន្តេវាសិក ឬរស់នៅជាមួយអ្នកដទៃទៀតជាអចិន្ត្រៃយ៍ ចូរកត់ត្រា "ទេ"។ តែបើក្មេងរស់នៅឆ្ងាយពីផ្ទះពិតមែន សំរាប់រយៈពេលខ្លីតែជាធម្មតារស់នៅជាមួយគ្រួសារ ចូរកត់ត្រា "បាទ/ចាស៎" ។

***សំនួរ២០៩:*** *អាយុពេលស្លាប់*

បើសិនមន្ត្រីសំភាសន៍អនុវត្តការរំលងសំនួរបានត្រឹមត្រូវ អ្នកត្រូវសួរសំនួរនេះ ចំពោះក្មេងដែលបានស្លាប់ទៅហើយ។ ចំពោះក្មេងដែលបានស្លាប់ មន្ត្រីសំភាសន៍ត្រូវកត់ត្រា ពតិមានអំពីអាយុក្មេងពេលស្លាប់ក្នុងសំនួរ២០៩ ទោះបីពតិមាននេះជាការប៉ាន់ស្មានក៏ដោយ។ ពតិមាន អំពីអាយុពេលស្លាប់ត្រូវកត់ត្រាជាថ្ងៃ ខែ ឬ ឆ្នាំ។

- បើក្មេងស្លាប់មានអាយុតិចជាងមួយខែ ចូរកត់ត្រាចំលើយជាថ្ងៃ។

- បើក្មេងស្លាប់មានអាយុតិចជាងពីរឆ្នាំ តែយ៉ាងតិចមានអាយុមួយខែឡើងពេលស្លាប់ ចូរកត់ត្រា កត់ត្រាចំលើយជាខែ។

- បើក្មេងស្លាប់មានអាយុចាប់ពីឆ្នាំឡើងទៅពេលស្លាប់ ចូរកត់ត្រាចំលើយជាឆ្នាំ។

*ចំនុចខ្លះត្រូវចងចាំក្នុងការបំពេញសំនួរ២០៩ :*

-ប្រើឯកតាពេញលេញ មន្ត្រីសំភាសន៍ត្រូវយកឯកតាពេញលេញមានន័យថាបើអ្នកឆ្លើយប្រាប់ថា ៤ខែកន្លះ, នោះត្រូវកត់ត្រា ៤ខែ។

-ប្តូរចំលើយពីសប្តាហ៍ទៅជាថ្ងៃ ឬជាខែ។ ចូរកត់សំគាល់ថាបើសិនជាអ្នកឆ្លើយ ផ្តល់ចំលើយជាសប្តាហ៍, នោះមន្ត្រីសំភាសន៍ត្រូវបង្វែរសប្តាហ៍ទៅជាថ្ងៃ ឬខែ។

. បើចំលើយតិចជាង១ខែ (តិចជាង៤សប្ដាហ៏ ), ចូរសួរយោងដើម្បី ទទួលបានអាយុជាក់ស្តែងពិតប្រាកដ ពេលស្លាប់គិតជាថ្ងៃ។ ឧទាហាណ៏ បើចំលើយឆ្លើយថា ៣សប្ដាហ៏, ចូរសួរយោងរកចំនួនថ្ងៃ។ ឧបមាថាម្ដាយឆ្លើយថា១៩ថ្ងៃ, ចូរកត់ត្រា ១៩ថ្ងៃ ។

. បើចំលើយចាប់ពី១ខែឡើងទៅ (៤សប្ដាហ៏ឡើងទៅ) មន្ត្រីសំភាសន៏ត្រូវប្ដូរចំលើយជាខែ។ ឧទាហរណ៏: បើចំលើយ ៧សប្ដាហ៏, ត្រូវកត់ត្រា ១ខែ ។

- សួរយោងបើចំលើយជា " ១ឆ្នាំ " ។ បើចំលើយបញ្ជាក់ថា១ឆ្នាំមន្ត្រីសំភាសន៏ត្រូវសួរយោងដើម្បីកំណត់យកចំនួនខែពិតប្រាកដ។ យើងដឹងថាបើក្មេងស្លាប់នៅអាយុ ១០ ១១ ១២ ១៣ ឬ១៤ខែនោះស្ត្រីទំនងជាអាចបង្រួមចំលើយអោយខ្លីព្រោះគាត់មិនដឹងថាយើងត្រូវការអាយុក្មេងជាក់ស្ដែង។ បញ្ហានេះ មានន័យថា គាត់ទំនងជាផ្ដល់ចំឡើយតែមួយឆ្នាំ ទោះបីជាក្មេងនោះមានអាយុពិតប្រាកដតែ ១០ខែ ឬ ១៣ខែ ក៏ដោយ។ ដូច្នេះរាល់ពេលដែលស្ត្រីឆ្លើយថាមួយឆ្នាំ ចំពោះសំនួរនេះគឺត្រូវសួររកចំនួនខែរបស់ក្មេង (ឈ្មោះ) ហើយ កត់ត្រាចំឡើយជាខែពេញលេញ។

ក្នុងការឆ្លើយតបទៅសំនួរនេះ, ស្ត្រីអាចឆ្លើយប្រាប់អ្នកសំភាសន៏ថា ទារកមិនមានជីវិតរស់នៅពេលទារកនោះកើត។ បើស្ត្រីឆ្លើយដូច្នេះ ចូរសួរសំនួរយោងថាតើទារកដែលកើតមកនោះបានយំ ឬបង្ហាញនូវសញ្ញានៃជីវិតរស់ដែលឬទេ ពេលទារកនោះកើតមក។ បើស្ត្រីឆ្លើយថាទារកស្លាប់ពេលទារកនោះកើតមក ចូរគូសសញ្ញាខ្វែងចូលក្នុងតារាងសំរាប់ទារកនេះ។ ចូរបញ្ជាក់ឱ្យច្បាស់ចំពោះការរាប់ឡើងវិញ នូវលេខលំដាប់កំនើតដែលបញ្ហានេះបានកើតឡើង។

***សំនួរ ២១០:*** *កំនើតរស់ក្នុងចន្លោះកំនើត*

គោលបំនងនៃសំនួរនេះគឺដើម្បី បញ្ជាក់ឱ្យច្បាស់ថាយើងអាចបានរំលងចំលើយរបស់អ្នកឆ្លើយអំពីការផ្ដល់កំនើតផ្ទាល់ខ្លួនរបស់គាត់ដែរឬទេ។ សូមសួរអ្នកឆ្លើយដើម្បីរកកំនើតរស់ណាមួយដែលបានកើតឡើងរវាងចន្លោះកំនើតពីរផ្សេងទៀត។ បើស្ត្រីប្រាប់ថា ពុំមានកំនើតផ្សេងទៀតទេ ចូរកត់ត្រា "ទេ" ក្នុងសំនួរ ២១០។ បន្ទាប់មកបន្ដសំនួរបន្ទាប់ ។

បើស្ត្រីប្រាប់ថា មានកំនើតផ្សេងទៀត ត្រូវកត់ត្រា "បាទ/ចាស់ " ក្នុងសំនួរ២១០ បន្ទាប់មកគូសសញ្ញាព្រួញបង្ហាញទីតាំងកំនើតដោយកំនត់នូវប្រវត្តិព្រឹត្តិការណ៏អោយបានសមស្រប ហើយកែរតំរូវលេខលំដាប់កំណើតក្នុងតារាងសំរាប់ក្មេងនោះ និង កំណើតទាំងអស់តាមលំដាប់លំដោយនៃប្រវត្តិព្រឹត្តិការណ៏ដែលបានកើតឡើង។

***បង្គោល (២១១-២១៥): ការថ្លឹងទំងន់ ការវាស់កំពស់ និង ការវាស់ដើមដៃកុមារ***

ការថ្លឹងទំងន់ ការវាស់កំពស់ និង ការវាស់ដើមដៃ ត្រូវអនុវត្តទីបន្ទាប់ពីបញ្ចប់ការសំភាសន៍ទាំងពីផ្នែក( ផ្នែកទីមួយ និងផ្នែកទីពីរ) ដោយអនុវត្តទៅតាមការណែនាំផ្នែកមនុស្សមាត្រនៃឯកសារណែនាំនេះ។

a) កត់ត្រាទំងន់កុមារ ជាគីឡូក្រាម

b) កត់ត្រាកំពស់កុមារ ជាសង់ទីម៉ែត្រ

c) កត់ត្រាដើមដៃកុមារ ជាសង់ទីម៉ែត្រ

*សំគាល់:* ចំពោះក្មេងអាយុក្រោម ៣ខែ មិនចាំបាច់វាស់ដើមដៃទេ។

***សំនួរ ២១៦: ខែ និងឆ្នាំកំណើតម្តាយ***

សំនួរ ២១៦ និង ២១៧ ឱ្យសួរផ្សេងពីគ្នា នៃពតិមានអំពីកំណើតម្តាយ ។ ទោះបីជាអ្នកបានសួររួចហើយ អំពីអាយុឆ្លើយតប នៅពេលដែលអ្នកបំពេញចប់សព្វគ្រប់តារាងសំនួរម្តាយ អ្នកត្រូវសួរគាត់ម្តងទៀតចំពោះថ្ងៃ ខែ ឆ្នាំកំណើត របស់គាត់នៅក្នុងសំនួរនេះ។

បើអ្នកឆ្លើយតបដឹងថ្ងៃខែឆ្នាំកំណើតរបស់គាត់ គិតជាឆ្នាំសកល ចូរសរសេរនៅក្នុងប្រអប់សមស្របសំរាប់ ខែ និងឆ្នាំ ។ អ្នកត្រូវបំលែងខែកំណើតដែលសរសេរជាអក្សរទៅជាលេខវិញ។ ឧទាហរណ៍ ខែមករា គឺ ០១ កុម្ភៈ ០២ មិនា ០៣ ហើយធ្វើដូច្នេះបន្តទៀត ហើយអ្នកត្រូវប្រើតារាងបំលែងខែប្រសិនបើអ្នកត្រូវការ។ ចូរសួរគាត់នូវ ឆ្នាំកំណើត ។ បើគាត់ដឹងឆ្នាំកំណើត ចូរសរសេរក្នុងប្រអប់ សំរាប់ឆ្នាំ។ នៅគ្រប់កាលទេសៈទាំងអស់ ចូរព្យាយាមទទួលយកអោយបាន យ៉ាងហោចណាស់ក៏ឆ្នាំកំណើតរបស់គាត់ដែរ ។

បើអ្នកឆ្លើយតបមិនអាចផ្តល់ពតិមាននេះបានទេ ចូរសួរគាត់ថា តើគាត់មាកឯកសារនានាដូចជាប័ណ្ណសំគាល់ខ្លួន លិខិតកំណើត ឈ្មោះ ដែលអាចផ្តល់ថ្ងៃខែឆ្នាំកំណើតរបស់គាត់ ។

***សំនួរ ២១៧: អាយុម្តាយ***

នេះគឺជាសំនួរមួយដ៏សំខាន់ ក្នុងការសំភាសន៍ ដោយហេតុថាស្ទើរគ្រប់ការវិភាគទាំងអស់នៃទិន្នន័យ អាស្រ័យទៅនឹងអាយុអ្នកឆ្លើយតប។ ឧទាហរណ៍ លទ្ធផលដ៏សំខាន់បំផុតពីរនៃអង្កេតគឺ អត្រាមានកូន ហើយនិងសមាមាត្រនៃស្ត្រីដែលប្រើផែនការគ្រួសារ ត្រូវបានគណនាទៅតាមអាយុនៃស្ត្រី ។

អ្នកត្រូវតែទទួលបានអាយុគាត់ជាឆ្នាំពេញគឺថា តើប៉ុន្មានឆ្នាំពេញដែលបានកន្លងទៅចាប់តាំងពីថ្ងៃ ខែ ឆ្នាំកំណើតរបស់គាត់។ អាយុរបស់មនុស្សម្នាក់នៅក្នុងប្រព័ន្ធឆ្នាំខ្មែរ គឺខុសគ្នាពីអាយុនៃប្រព័ន្ធ

ឆ្នាំលោកខាងលិច។ តាមប្រព័ន្ធលោកខាងលិច នៅពេលក្មេងកើតភ្លាមគឺមានអាយុ 0 ឆ្នាំ ។ គឺមានតែមួយឆ្នាំកន្លងទៅទើបអាយុកុមារមានអាយុ ១ឆ្នាំ។ ត្រូវមានការប្រុងប្រយ័ត្នក្នុងការកត់ត្រាអាយុនៃស្ត្រី ។ អ្នកត្រូវតែកត់ត្រាអាយុស្ត្រីហើយ អ្នកអាចធ្វើដូចនេះ ដោយវិធី៤យ៉ាង អាស្រ័យទៅតាមប្រភេទនៃពតិមាន ដែលអ្នកទទួលពីអ្នកឆ្លើយតប ។

### ***១- បើស្ត្រីដឹងអាយុរបស់គាត់ ចូរកត់ត្រាចំលើយ***

a)បើអាយុគាត់និងថ្ងៃខែឆ្នាំកំណើតសកល

ចូរពិនិត្យរកមើលភាពស៊ីគ្នារវាងថ្ងៃខែឆ្នាំកំណើតនិងអាយុរបស់គាត់។ អ្នកអាចពិនិត្យរកភាពស៊ីគ្នាដោយបូកអាយុរបស់គាត់ នៅនិងឆ្នាំកំណើតរបស់គាត់ ។ ឧទាហរណ៍ បើអ្នកឆ្លើយតបប្រាប់អ្នកថា គាត់កើតខែមករា ឆ្នាំ ១៩៧0 ហើយគាត់ថា គាត់មានអាយុ ៣0ឆ្នាំ ហើយអ្នកសំភាសន៏គាត់ក្នុង ខែកុម្ភៈ ២000 អ្នកអាចបូក ១៩៧0 ជាមួយ និង ៣0 ។ បើពតិមានដែលអ្នកឆ្លើយតបឱ្យវាស៊ីគ្នា លទ្ធផលបូកគឺ ២000 ដោយ ខែកុម្ភៈបន្ទាប់ពីខែ មករា ។

បើអ្នកឆ្លើយតបផ្សេងទៀត ប្រាប់អ្នកថាគាត់កើតខែ ឧសភា ១៩៦៨ ហើយគាត់អាយុ ៣១ឆ្នាំ ការបូកត្រូវស្មើគ្នា ( ១៩៩៩ = ១៩៦៨ + ៣១ ) ដោយហេតុថាគាត់និងមិនទាន់បានពេញមួយឆ្នាំ ទាល់តែដល់ខែ ឧសភា សិន ( ខែកុម្ភៈ មុនខែឧសភា ) ។

b) បើគាត់មិនដឹងខែឆ្នាំសកល ចូរសួរថ្ងៃខែឆ្នាំ ខ្មែរដើម្បីពិនិត្យមើលភាពស៊ីគ្នារវាង ថ្ងៃខែ ឆ្នាំកំណើត និងអាយុ គាត់។ ចូរសរសេរ ខែ ឆ្នាំ ខ្មែរ នៅលើបន្ទាត់ក្រោមសំណួរ ១0៦។ ដំបូងចូរបំលែងខែខ្មែរជា ខែ សកល។ បន្ទាប់មក ចូររកអាយុគាត់ នៅលើតារាងបំលែង អាយុ ។ ចូរប្រើខែ សកល ដើម្បីជួយសំរេច បើគាត់ កើតនៅក្រោយ ឬ មុនរដូវច្រូតកាត់ ។ បើគាត់បញ្ជាក់ អាយុគាត់ក្នុងចន្លោះលើស ឬខ្វះ មួយឆ្នាំ នៃការគណនាអាយុគាត់ មិនត្រូវផ្លាស់ប្តូរ អាយុដែលបានកត់ត្រាឡើយ ហើយចូរបន្ត ។ បើអាយុដែលគាត់ប្រាប់ពីរ ឬ ច្រើនឆ្នាំ នៅលើ ឬ ក្រោមអាយុដែលបានគណនា ចូរសួរយោង ដើម្បីរកមើលពតិមានដ៏ត្រឹមត្រូវបំផុត ។ ចូរសួរអ្នកឆ្លើយតប បើគាត់ច្បាស់លាស់ អំពីអាយុគាត់ ឬ ថ្ងៃខែឆ្នាំកំណើត គាត់ បន្ទាប់ពីបានរកឃើញចំលើយមួយជាក់លាក់ ចូរកត់ត្រាចំលើយនោះ ក្នុងប្រអប់អាយុ ជាឆ្នាំពេញ ។

### ***២. បើស្ត្រីមិនដឹងអាយុគាត់ ចូរធ្វើតាមវិធីខាងក្រោមដើម្បីរកអាយុគាត់***

a-បើគាត់ដឹង ថ្ងៃខែឆ្នាំសកល ចូរប្រើ តារាងបំលែង ឆ្នាំ និង តារាងបំលែង ខែ ដើម្បីគណនាអាយុគាត់ ។

b-បើគាត់ដឹងថ្ងៃខែឆ្នាំ ខ្មែរ អ្នកអាចគណនាអាយុ គាត់ដូចដែលបានរៀបរាប់ខាងលើ ។ ចូរសរសេរ ខែ ខ្មែរ ឆ្នាំ ខ្មែរ នៅលើបន្ទាត់ពីក្រោមសំណួរ ២១៧ ។ ដំបូងបំលែងខែខ្មែរ ទៅជាខែសកល ។ បន្ទាប់មកចូររកមើលអាយុរបស់គាត់នៅលើតារាងបំលែង ឆ្នាំ ។ បើអាយុដែលគាត់បញ្ជាក់ប្រាប់ពីឆ្នាំ ឬ ច្រើនជាង ឬក្រោមអាយុ ដែលបានគណនា មិនត្រូវប្តូរអាយុគាត់ដែលបានកត់ត្រាទេ ត្រូវធ្វើការបំលែង បន្តទៀត ។ បើអាយុដែលគាត់បញ្ជាក់ប្រាប់ច្រើនជាង ឬនៅក្រោមអាយុដែលបានគណនា ចូរសួរយោង ដើម្បីរកមើលពត៌មានដ៏ត្រឹមត្រូវបំផុត ។ ចូរកត់ត្រាពត៌មាននៅក្នុងប្រអប់អាយុជាឆ្នាំពេញ ។

C-បើស្រ្តីមិនដឹងថ្ងៃខែឆ្នាំកំណើតគាត់ អ្នកនិងសួរយោងដើម្បីប៉ាន់ស្មានអាយុរបស់គាត់ ។ ការ សួរយោងរកអាយុគាត់គឺប្រើពេលវេលាច្រើន ហើយពេលខ្លះតឹងតែង ទោះជាយ៉ាងណាក៏ដោយ វាសំខាន់ ណាស់អ្នកត្រូវប្រើពេលវេលាដើម្បីព្យាយាមទទួលបានពត៌មានមួយដ៏ត្រឹមត្រូវបំផុត ដែលអាចធ្វើបាន ។ មានវិធីច្រើនដើម្បីសួរយោង អាយុ ។

ចូរសួរអ្នកឆ្លើយតប តើគាត់អាយុប៉ុន្មានឆ្នាំនៅពេលគាត់រៀបការ មានកូនដំបូង ហើយបន្ទាប់មក ព្យាយាមប៉ាន់ស្មាន តើរយៈពេលប៉ុន្មានហើយដែលគាត់រៀបការឬមានកូនលើកដំបូង ។ ឧទាហរណ៏ បើ គាត់និយាយថា គាត់មានអាយុ ១៩ឆ្នាំ នៅពេលនេះមានកូនដំបូង ហើយកូនគាត់មានអាយុ ១២ឆ្នាំ ហើយ ដូច្នេះគាត់ប្រហែលមានអាយុ៣១ឆ្នាំហើយ ។ អ្នកត្រូវព្យាយាមប្រៀបធៀបអាយុគាត់ទៅនឹងអ្នក ផ្សេងទៀតនៅក្នុងគ្រួសារ ដែលអាយុរបស់គាត់អាចយកជាការបាន ។

ព្យាយមសួររកមើលថា តើគាត់មានអាយុប៉ុន្មាននៅពេលមានព្រឹត្តិការណ៏សំខាន់ដូចជា សង្រ្គាម ទឹកជំនន់ ការផ្លាស់ប្តូររបបនយោបាយ ហើយបូកអាយុគាត់នាពេលនោះ និងចំនួនឆ្នាំដែលបានកន្លងមក រាប់ពីមានព្រឹត្តិការណ៏នោះ ។ ចូរប្រើតារាងប្រវត្តិសាស្រ្តដើម្បីជួយប្រៀបធៀបអាយុគាត់ ហើយ និង ឆ្នាំកំណើតនៃព្រឹត្តិការណ៏ប្រវត្តិសាស្រ្ត ។

បើអ្នកយោងមិនឆ្ងាយក្នុងការកំណត់អាយុ អ្នកឆ្លើយតប ហើយនិងការបរិច្ឆេទនៃកំណើតដែល មិនបានកត់ត្រាក្នុងសំនួរ ២១៦ អ្នកនឹងត្រូវប៉ាន់ស្មានអាយុគាត់ ចូរចាំថា នេះជាវិធីចុងក្រោយបំផុត ដើម្បី ប្រើប្រាស់ បើរាល់ការព្យាយាមរបស់អ្នកក្នុងការសួរយោងបរាជ័យ ។

ចូរចាំថា អ្នកត្រូវតែបំពេញសំណួរ២១៧ ។ មិនត្រូវពិនិត្យមើលភាពស៊ីគ្នារវាងអាយុ ដែលបាន កត់ត្រាក្នុងសំនួរម្តាយនិងសំនួរនេះទេ ។ អ្នកត្រូវត្រលប់ទៅកែពត៌មាន ដែលបានកត់នៅលើតារាងសំនួរ ម្តាយ គឺនិងត្រូវតែពត៌មានដែល ប៉ះពាល់ស្ថានភាពអាចជ្រើសរើសសំភាសន៏បាននៃស្រ្តី ។

***សំនួរ ២១៨:*** *ធ្លាប់ចូលរៀន*

ពាក្យថាសាលារៀនមានន័យថា សាលារៀនផ្លូវការ រួមមានបឋមសិក្សា មធ្យមសិក្សា និង ក្រោយមធ្យមសិក្សា ហើយនិងកំរិតផ្សេងទៀតនៃការរៀននៅក្នុងប្រព័ន្ធអប់រំផ្លូវការ។ និយមន័យនៃ សាលារៀន មិនរួមបញ្ចូល សាលាគម្ពីសាសនាគ្រីស្ត សាលាកូរ៉ាន់ ឬមុខវិជ្ជាខ្លីៗដូចជាវាយកំព្យូទ័រ ឬដេរប៉ាក់។ ប៉ុន្តែវារួមបញ្ចូលការបណ្តុះបណ្តាលបច្ចេកទេស ឬវិជ្ជាជីវៈ លើសពីកំរិតបឋមសិក្សាដូចជា មុខវិជ្ជារយៈពេលវែងផ្នែកមេកានិច ឬការងារលេខា។

***សំនួរ ២១៩:*** *កំរិតខ្ពស់បំផុតនៃការសិក្សា*

កត់ត្រាកំរិតខ្ពស់បំផុត ដែលគាត់បានសិក្សា ទោះបីថារៀនចប់ ឬមិនបានរៀនចប់ឆ្នាំពេញ លេញ។ ឧទាហរណ៏ៈ បើគាត់រៀនមធ្យមសិក្សាបានតែពីរសប្តាហ៏ ចូរកត់ត្រាមធ្យមសិក្សា។

***សំនួរ ២២០:*** *ថ្នាក់ខ្ពស់បំផុតចប់ពេញលេញ*

ចំពោះសំណួរនេះកត់ត្រាតែចំនួនឆ្នាំដែលអ្នកឆ្លើយតបបានបញ្ចប់ដោយជោគជ័យនៅកំរិតនោះ។ ឧទាហរណ៏ៈ បើស្ត្រីកំពុងរៀនថ្នាក់ទី៣ នៃបឋមសិក្សាហើយបានឈប់រៀនមុនពេលបញ្ចប់ឆ្នាំពេញលេញ ចូរកត់ត្រាថ្នាក់ទី២ ទោះបីជាថ្នាក់ទី៣ជាឆ្នាំសិក្សាខ្ពស់បំផុតដែលគាត់បានរៀន ប៉ុន្តែគាត់បានបញ្ចប់ឆ្នាំ ពេញលេញតែ២ឆ្នាំនៃបឋមសិក្សា។

ចូរចាំថាអ្នកនិងកត់ត្រា ចំនួននៃឆ្នាំពេញលេញ នៅកំរិតដែលបានកត់ត្រាក្នុងសំណួរ ១០៨ ។

ឧទាហរណិ៍ បើគាត់បានរៀនតែ ២អាទិត្យនៃថ្នាក់ទី១ នៃមធ្យមសិក្សាកត់ត្រា "00" សំរាប់ឆ្នាំ ពេញលេញ ។

***សំនួរ ២២១:*** *ការពិនិត្យស្ថានភាពអាពាហ៏ពិពាហ៏*

ការពិនិត្យនេះ ទាមទារអោយអ្នកផ្នែកពិនិត្យសំនួរ ២២១ និង ២២៤ នឹងគូសសំគាល់ពីស្ថានភាព អាពាហ៏ពិពាហ៏ របស់អ្នកឆ្លើយ។ ចំពោះស្ត្រីដែលធ្លាប់រៀបការ ឬរស់នៅជាមួយដៃគូរ អ្នកចាំបាច់ ត្រូវប្រើពាក្យសំនួរក្នុងពេលបច្ចុប្បន្ន នឹងក្នុងអតីតកាល ទៅតាមស្ថានភាពអាពាហ៏ពិពាហ៏របស់ស្ត្រី។ ចំពោះស្ត្រីដែលធ្លាប់មានប្តី(ដៃគូរ)លើសពីមួយ អ្នកត្រូវសួរពីប្តីបច្ចុប្បន្ន ប្តីចុងក្រោយ(ដៃគូរ)។

***សំនួរ ២២២-២២៣:*** *ការសិក្សារបស់ប្តី*

សំនួរទាំងនេះ សួរអំពីអ្នកឆ្លើយ ។ ក្នុងសំនួរ ២២៣ អ្នកសំភាសន៏ត្រូវកត់ត្រានូវកំរិតសិក្សាខ្ពស់ បំផុតដែលបានបញ្ចប់នូវកំរិតសិក្សានេះ។

***សំនួរ ២២៤:*** *ប្រភេទការងារបច្ចុប្បន្ន(ឬ ថ្មីៗ)របស់ប្តី*

ដំបូងសូមពិនិត្យសំនួរ២២១។ បើស្ត្រីម្នាក់បច្ចុប្បន្នមានប្តី ឬកំពុងរស់នៅជាមួយបុរសម្នាក់ សួរមុខរបរប្តី ឬដៃគូរ។ បើគាត់បច្ចុប្បន្នគ្មានប្តី ប៉ុន្តែធ្លាប់មានប្តី ឬធ្លាប់រស់នៅជាមួយបុរសម្នាក់ សួរពីមុខរបររបស់ប្តី ឬដៃគូរក្នុងពេលថ្មីៗនេះ។

យើងមិនយកចិត្តទុកដាក់ក្នុងវិស័យដែលប្តីបានធ្វើទេ (ឧទាហរណ៍ កសិកម្ម រ៉ែ ឬ លក់ដូរ) ឬកន្លែងប្តីធ្វើការ(នៅធនាគារ ហាងលក់សំលៀកបំពាក់ ឬការិយាល័យរដ្ឋាភិបាល) ប៉ុន្តែយើងចង់ដឹងអំពីការងារប្តីជាអ្វី (ឧទាហរណ៍ នៃមុខរបរ គឺស្មៀន លេខា ជាងកាត់សក់ អ្នកបើកបរតាក់ស៊ី គ្រូពេទ្យ គ្រូបង្រៀន អ្នកច្បាប់ អ្នកលក់ដូរ អ្នកនេសាទ អ្នកស្រែ ជាងគំនូរ ។ល។

សូមសរសេរចំលើយជាពាក្យផ្ទាល់របស់អ្នកឆ្លើយ។ ឧទាហរណ៍ បើអ្នកឆ្លើយនិយាយថា ប្តីធ្វើការនៅក្រសួងផែនការ សួរថាតើបុរសនោះធ្វើអ្វីនៅទីនោះ។ បើអ្នកមិនច្បាស់ពីការសរសេរមុខរបរ វាជាការប្រសើរ ត្រូវផ្តល់នូវសេចក្តីលំអិត។

"បច្ចុប្បន្នមិនធ្វើការ " វាមិនជាចំលើយទទួលយល់ព្រមនោះទេ គឺប្តីគ្មានការងារធ្វើ។ បើគាត់ធ្វើការច្រើនជាងមួយ សូមសរសេរមុខរបរដែលគាត់ចំណាយពេលច្រើនជាងគេ។ បើគាត់គ្មាន ការងារទេ ព្រោះគាត់នៅរៀនសូមសរសេរ "សិស្ស ឬនិស្សិត "។ សូមកុំបំពេញក្នុងប្រអប់ កូតទាំងពីរ ក្នុងសំនួរនេះ ព្រោះកូតត្រូវចុះនៅពេលក្រោយ ដោយអ្នកកែដៃ។

***សំនួរ ២២៥-២២៧:*** *ភាពមានការងារ និងមុខរបរ*

សំនួរទាំងនេះ គឺជាប់ទាក់ទងនឹងការងារណាមួយជាជាងកិច្ចការផ្ទះដែលអ្នកឆ្លើយធ្វើ។ សំនួរ ២២៦ ត្រូវបានបញ្ចូល ព្រោះវាកើតឡើងញឹកញាប់ គឺស្ត្រីលក់ដូរ ឬធ្វើការនៅកសិដ្ឋានរបស់គ្រួសារ និងមិនពិចារណានូវអ្វីដែលគេធ្វើ ជាពិសេសបើគេមិនទទួលបានកំរៃពីការងារ។ សូមអានឃ្លាសេចក្តីផ្តើមនៃសំនួរ ២២៦ ដូចនេះអ្នកឆ្លើយយល់ពីរអ្វីដែលមាននៃតាមការងារ ។

ចំពោះស្ត្រីដែលកំពុងមានការងារ ក្នុងសំនួរ២២៧ អ្នកនឹងកត់ត្រាមុខរបរស្ត្រីដូចគ្នាក្នុងសំនួរ ២២៤ ចូរសរសេរមុខរបរស្ត្រីតាមសំដីរបស់គាត់ ។ វាជាការប្រសើរដោយផ្តល់នូវការលំអិត។

***សំនួរ ២២៨ :*** *ត្រួតពិនិត្យ ការងារកសិកម្ម ឬការងារផ្សេងទៀត?*

ការងារកសិកម្មរួមមាន ចំការ ចិញ្ចឹមសត្វ (រួមមាន សត្វស្រុក បក្សី នឹង ត្រី) ការងារនេសាទ ការងារបបាញ់ បើកត្រាក់ទ័រនៅចំការ ឬសកម្មភាពផ្សេងៗទៀត ដែលទាក់ទងការដាំដុះ ឬប្រមូលផល ។

បើការងារស្ត្រី គឺលក់ម្ហូបអាហារ តែគាត់មិនមែនជាអ្នកផលិតទេ គាត់មិនត្រូវបានគិតថា គាត់ជាកសិករទេ។ បើស្ត្រី គ្រាន់តែដាំដំណាំពីរ ឬបីមុខ តែមានការងារផ្សេង នោះមិនមែនធ្វើការខាងកសិកម្មទេ ។

***សំនួរ ២២៩:*** *ធ្វើការលើដីគ្រួសារ ឬ ដីអ្នកផ្សេងទៀត*

សំនួរនេះគឺសួរស្ត្រីដែលធ្វើការខាងកសិកម្មដើម្បីកំនត់កម្មសិទ្ធដីដែលគាត់ធ្វើការ ។ បើស្ត្រីធ្វើការជាចំបងនៅលើដីកម្មសិទ្ធផ្ទាល់ខ្លួន ឬដីកម្មសិទ្ធរបស់ប្តី ឬកូន សូមកត់ត្រា "ដីខ្លួនឯងផ្ទាល់ "។ បើស្ត្រីធ្វើការ នៅលើដីកម្មសិទ្ធរបស់សមាជិកគ្រួសារអ្នកដទៃ ឬគ្រួសាររបស់ប្តី សូមកត់ត្រា " ដីគ្រួសារ "។ បើដីជួលគេ សូមកត់ត្រា " ដីជួល "។ បើស្ត្រីជាអ្នកធ្វើការនៅលើដីអ្នកផ្សេងទៀត សូមកត់ត្រា " ដីអ្នកផ្សេងទៀត ។

***សំនួរ ២៣០-២៣១:*** *ការមានផ្ទៃពោះក្នុងពេលបច្ចុប្បន្ន និងកន្លែងផ្តល់សេវាកម្មពិនិត្យផ្ទៃពោះ*

សំនួរនេះ គឺសួរអំពីការត្រួតពិនិត្យផ្ទៃពោះ ដែលផ្តល់ដោយមន្ត្រីថែទាំសុខភាពក្នុងកំឡុងពេលមានផ្ទៃពោះ។ ការថែទាំសុខភាព គឺសំដៅលើការពិនិត្យផ្ទៃពោះ គឺមិនមែនសំរាប់មូលហេតុផ្សេងៗទៀត។ សំនួរនេះគឺមានពីរផ្នែក បើអ្នកឆ្លើយ ឆ្លើយថា "ចាស់ " នោះមន្ត្រីសំភាសន៏ត្រូវសួរថា តើពេលពិនិត្យផ្ទៃពោះទៅជួបអ្នកណា។ ដោយសារយើងត្រូវការសួរអ្នកដែលស្ត្រីបានជួបដើម្បីពិនិត្យផ្ទៃពោះទាំងអស់ ចូលអានសំនួរបន្ថែមទៀតថា តើមានអ្នកផ្សេងទៀតទេ? ដើម្បីបញ្ជាក់ ច្បាស់អំពីអ្នកដែលបានផ្តល់ការពិនិត្យផ្ទៃពោះដល់ស្ត្រី។

***សំនួរ ២៣២:*** *ចំនួនពេលវេលានៃការពិនិត្យផ្ទៃពោះ*

សួរថា តើស្ត្រីទៅពិនិត្យផ្ទៃពោះសរុបចំនួនប៉ុន្មានដង ក្នុងពេលមានផ្ទៃពោះ សំនួរនេះ គឺទាក់ទងនឹងការមានផ្ទៃពោះប៉ុណ្ណោះ គឺមិនគិតពីការទៅជួបគ្រូពេទ្យ ឬ គិលានុប្បដ្ឋាកដើម្បីពិនិត្យសុខភាពផ្សេងទៀតឡើយ។

***សំនួរ ២៣៣- ២៣៤:*** *ថ្នាំគ្រាប់ជាតិដែក*

សួរថាតើ ស្ត្រីបានទទួលថ្នាំជាតិដែកដែរឬទេ ពេលមានផ្ទៃពោះ។ បើស្ត្រីមិនស្គាល់ថ្នាំប្រភេទ នេះចូរបង្ហាញប្រភេទថ្នាំគ្រាប់នេះទៅគាត់ដើម្បីទទួលបានចំលើយត្រឹមត្រូវ។ ចូរកំនត់ចំណាំថា: ថ្នាំគ្រាប់ជាតិដែកដែលគាត់ប្រើនេះ អាចជាថ្នាំដែលគាត់ទទួលបាន ឬទិញសំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ពេលគាត់មានផ្ទៃពោះ។

បើអ្នកឆ្លើយបានទទួល ឬទិញថ្នាំជាតិដែក (ចាស ក្នុងសំនួរ២៣៣) ចូរសួរគាត់ តើគាត់បានទទួលថ្នាំគ្រាប់ចំនួនប៉ុន្មានថ្ងៃក្នុងកំឡុងពេលមានផ្ទៃពោះ។ បើសិនគាត់មិនចាំ ចូរសួរគាត់អោយប៉ាន់ស្មាន។ ចូរសួរយោងដើម្បីរកចំនួនថ្ងៃប្រហាក់ប្រហែល ហើយកត់ត្រាចំលើយក្នុងប្រអប់។ ចូរចាំថាកត់ត្រាលេខ០មុន ឧទាហរណ៍ ៣០ថ្ងៃ ត្រូវកត់ត្រា ០៣០។

***សំនួរ ២៣៥:*** *ជម្ងឺសត្វល្អិតក្នុងពោះវៀន:* អនុវត្តទៅតាមសេចក្តីណែនាំក្នុងតារាងសំនួរ។

***សំនួរ ២៣៦ - ២៣៧:*** *បញ្ហាពិបាកក្នុងការមើលពេលមានផ្ទៃពោះ*

សំនួរនេះចង់ដឹងថា តើអ្នកឆ្លើយមានបញ្ហាលំបាកក្នុងការមើលពេលមានផ្ទៃពោះ នៅពេលណាមួយដែរឬទេ។ ក្នុងកំឡុងពេលមានផ្ទៃពោះ ពិសេសនៅក្នុងដំណាក់កាលទី៣ នៃរយះពេលមានផ្ទៃពោះ គឺពេលនោះស្ត្រីអាចទទួលរាប់រងនូវជំងឺដោយសារការខ្វះជាតិវីតាមីន A។ ជំងឺខ្វាក់មាន់ជាជំងឺមួយដែលធ្វើអោយគាត់មានការលំបាកមើលខុសពីធម្មតាពេលមេឃងងឹត ឬពន្លឺមិនគ្រប់គ្រាន់។

ក្នុងសំនួរ២៣៦ ចូរសួរអ្នកឆ្លើយថា តើគាត់ទទួលរងនូវបញ្ហាក្នុងការមើលដែរឬទេ នៅពេលថ្ងៃ ឧទាហរណ៍ ព្រិលភ្នែក។ កុំរាប់បញ្ចូលបញ្ហាដូចជា ការមើលឃើញជិត តែមិនឃើញឆ្ងាយ ឬការមើលឃើញឆ្ងាយ តែមិនឃើញជិត។ ក្នុងសំនួរ២៣៧ ចូរសួរអំពីជំងឺខ្វាក់មាន់។ ចូរប្រើពាក្យសំរាយដើម្បីងាយយល់ចំពោះជំងឺខ្វាក់មាន់ដើម្បីអោយស្ត្រីអាចយល់បានអំពីជំងឺនេះ។

***សំនួរ ២៣៨:*** *វីតាមីន A*

បង្ហាញគ្រាប់វីតាមីន A ដោយសួរស្ត្រីអ្នកឆ្លើយថា តើគាត់បានទទួលថ្នាំវីតាមីន A ប្រភេទដូចនេះដែរឬទេ ក្នុងរយះពេល៦សប្តាហ៍ក្រោយសំរាលកូន។

***សំនួរ ២៣៩: ថ្នាំជាតិដែក:*** *អនុវត្តទៅតាមសេចក្តីក្នុងតារាងសំនួរ។*

***សំនួរ ២៤០ - ២៤១:*** *ទំងន់ទារកពេលកើត*

សំនួរទាំងនេះ សួរអំពីពតិមានថា តើទារកដែលកើតមក បានថ្លឹងទំងន់ដែរឬទេ បើបានថ្លឹងចូរសួរអំពីទំងន់របស់ទារកនោះ។ ចូរចំណាំថា ក្នុងសំនួរ២៤១ មានប្រអប់ពីរសំរាប់កត់ត្រាទំងន់ពេលកើត ទី១គឺកត់ត្រាទំងន់ជាគីឡូក្រាមពីបណ្ណ័ និង ទី២គឺកត់ត្រាពីគីឡូក្រាមតាមការចាំរបស់ម្តាយ។ គីឡូក្រាមពីបណ្ណ័ គឺទាក់ទងទៅដល់ការកត់ត្រាទំងន់ពីកំនើតដែលមាននៅក្នុងឯកសារ ដូចជា បណ្ណ័ចាក់វ៉ាក់សាំង បណ្ណ័ពិនិត្យផ្ទៃពោះ សំបុត្រកំនើត ឬគីឡូក្រាមពីការចងចាំនៅពេលកើតមក។ បើអាចមានលទ្ធភាព ចូរកត់ត្រាតែទំងន់កូនកើតពីបណ្ណ័តែប៉ុណ្ណោះ។ មន្ត្រីសំភាសន៏អាចកត់ត្រាទំងន់កូនពេលកើត

ដោយការចង់ចាំរបស់ម្តាយគិតជាគីឡូក្រាមក្នុងករណីដែលពុំមានបណ្ណ័ ឬពុំមានទំងន់ពេលកើតកត់ត្រាក្នុងបណ្ណ័។

ពេលកត់ត្រាទំងន់កំនើត ដំបូងចូរគូសរង្វង់លេខកូតសមស្រប លេខ១=គីឡូក្រាមពីបណ្ណ័ ហើយលេខ២=គីឡូក្រាមពីការចងចាំរបស់ម្តាយ បន្ទាប់មកកត់ត្រាទំងន់។ បើសិនជាពុំមានទំងន់ កត់ត្រាក្នុងបណ្ណ័ ហើយស្រ្តីមិនអាចចងចាំពីទំងន់ពេលកើតពិតប្រាកដ ចូលសួរគាត់អោយផ្តល់ ចំលើយប៉ាន់ស្មាន។ កត់ត្រាមិនដឹងលុះត្រាតែគាត់មិនអាចចងចាំបាន ឬមិនអាចប៉ាន់ស្មានបាន។

***សំនួរ ២៤២:*** *ជំងឺរាគក្នុងរយះពេល២សប្តាហ៏កន្លងមក*

ជំងឺរាគ គឺជាមូលហេតុចំបងដែលបណ្តាលអោយកើតជំងឺផ្សេងៗ និងសេចក្តីស្លាប់ក្នុងចំណោមកុមារក្មេងៗនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ បើអ្នកឆ្លើយមិនច្បាស់អំពីជំងឺរាគ ចូរពន្យល់គាត់ថា "ការបត់ជើងធំ ដែលមានលាមករាវច្រើនជាងបីដងក្នុង១ថ្ងៃ "។ ពេលអានសំនួរនេះ ចូរបញ្ជាក់ពីពេល២ សប្តាហ៏កន្លងមក។

***សំនួរ ២៤៣:*** *ជំងឺរាគមានឈាម*

ត្រូវសួរថា តើមានឈាមក្នុងលាមកដែលឬទេ? ឈាមនៅក្នុងលាមកគឺជារោគសញ្ញានៃជំងឺរាករូស ដែលបណ្តាលមកពីបាក់តេរី។

***សំនួរ ២៤៤:*** *អាការះបច្ចុប្បន្ននៃជំងឺរាគ*

សំនួរអាចផ្តល់ពតិមានអំពីអត្រាកើតជំងឺរាកនៅពេលធ្វើអង្កេត។

***សំនួរ ២៤៥:*** *ជំងឺគ្រុនក្នុងរយះពេល២សប្តាហ៏កន្លងមក*

ជំងឺគ្រុន គឺជាមេរោគគ្រុនចាញ់ និងហើមសួត ដែលជាមូលហេតុបណ្តាលអោយកុមារក្មេងៗស្លាប់បានក្នុងប្រទេសជាច្រើន។ ចូរកត់ត្រា "ចាស់ " បើមានជំងឺគ្រុនកើតឡើងក្នុងរយះពេល ២ សប្តាហ៏មុនការបរិច្ឆេទសំភាសន៏។

***សំនួរ ២៤៦-២៤៧:*** *ជំងឺក្អកក្នុងរយះពេល២សប្តាហ៏កន្លងមក*

សំនួរ ២៤៦: ចូរកត់ត្រា "ចាស់ " បើមានជំងឺក្អកកើតឡើងក្នុងរយះពេល ២សប្តាស៏មុនការបរិច្ឆេទសំភាសន៏។ សំនួរ ២៤៧: សំនួរនេះត្រូវសួរតែក្មេងដែលមានជំងឺក្អក ក្នុងរយះពេល ២សប្តាស៏កន្លងមក។ ជំងឺហើមសួត នឹង ជំងឺប្រដាប់ដង្ហើម គឺអាចរួមផ្សំជាមួយការដកដង្ហើមខ្លី ឬញាប់ដែលជាមូលហេតុសំខាន់អាចអោយក្មេងស្លាប់បាន។

***សំនួរ ២៤៨:*** *ការបែងចែកជំងឺធ្ងន់ធ្ងរ និងជំងឺប្រដាប់ដកដង្ហើម*

គោលបំណងចំពោះសំនួរនេះ គឺត្រូវបែងចែកអោយដាច់ស្រឡះពីគ្នា អំពីជំងឺដែលបង្កបញ្ហាដល់ជីវិត នឹងជំងឺហៀរសំបោរដែលពុំសូវមានបញ្ហាធ្ងន់ធ្ងរ ។

***សំនួរ ២៤៩-២៥០:*** *វីតាមីនA*

បង្ហាញក្រាប់វីតាមីន A ដោយសួរស្ត្រីអ្នកឆ្លើយថា តើកូនគាត់បានទទួលថ្នាំវីតាមីន A ប្រភេទដូចនេះដែរឬទេ? ក្នុងសំនួរ២៥០ កត់ត្រាចំនួនខែដែលបានកន្លងផុតទៅចាប់តាំងពីកូន គាត់បានទទួលវីតាមីនចុងក្រោយ ។ បើចំនួនខែតិចជាង១ខែ ចូរចុះលេខ "00" ក្នុងប្រអប់ទី១ ។

***សំនួរ ២៥១:*** *ជម្ងឺសត្វល្អិតក្នុងពោះវៀន:* អនុវត្តទៅតាមសេចក្តីណែនាំក្នុងតារាងសំនួរ ។

***សំនួរ ២៥២:*** *ការនៅបំបៅដោះកូនបន្ត*

ចូរកត់ត្រាសំគាល់ថា សំនួរនេះគឺមិនគិតថា ស្ត្រីបានផ្តល់សារជាតិរាវផ្សេងទៀត ឬអាហាររឹង និងការបំបៅដោះទេ ។ យើងចង់ដឹងថា តើក្មេងនៅបៅដោះម្តាយដែរឬទេ ។

***សំនួរ ២៥៣- ២៥៤:*** *ការបំបៅដោះកូននៅពេលថ្ងៃ និងពេលយប់*

សំនួរនេះ សួរតែក្មេងដែលនៅបំបៅដោះម្តាយតែប៉ុណ្ណោះ ។ កំនត់ចំលើយក្នុងសំនួរ២៥៣ បើការបំបៅដោះនៅពេលយប់វិញ តើស្ត្រីបានបំបៅដោះកូនបានប៉ុន្មានដង ។ គឺរវាងពីពេលព្រលប់ដល់ព្រលឹម បើសិនជាគាត់អោយចំណីកូនតាមតំរូវការ ឬគាត់មិនចាំចំនួនដងនៃការបំបៅដោះកូនកាលពីយប់មិញ ចូរសួរអោយគាត់ផ្តល់ចំលើយប៉ាន់ស្មាន ។ ក្នុងសំនួរ២៥៤ យើងចង់ដឹងចំនួនដងនៃការបំបៅដោះកូន កាលពីម្សិលមិញគឺក្នុងកំឡុងពេលថ្ងៃ ពីព្រលឹមដល់ព្រលប់ បើគាត់មិនប្រាកដច្បាស់លាស់ សូមសួរអោយគាត់ផ្តល់ចំលើយប៉ាន់ស្មានម្តងទៀត ។

***សំនួរ ២៥៥ - ២៥៦:*** *ការផ្តល់វត្ថុរាវ នឹងអាហារដល់កូនកាលពីម្សិលមិញ*

គោលបំណងនៃសំនួរនេះ គឺដើម្បីបញ្ជាក់ពីប្រភេទនៃរបបអាហារច្បាស់លាស់ ដែលផ្តល់អោយកូន។ សំនួរនេះ គឺមានបំណង សួរអំពីកូនក្មេងបំផុតដែលកើតចាប់ពីខែ វិច្ឆិកា ឆ្នាំ២០០៣។ ក្នុងសំនួរ២៥៥ យើងសួរម្តាយអំពីប្រភេទនៃវត្ថុ នឹងសំនួរ២៥៦ អំពីប្រភេទអាហារ ដែលបានផ្តល់អោយកូនក្នុងរយះពេល២៤ម៉ោង មុនការសំភាសន៏។ ក្នុងសំនួរនេះ អាហារទាំងអស់ ត្រូវបានបែងចែកតាមក៏រិតអាហាររូបត្ថម្ភខ្ពស់បំផុត ។

***ត្រួតពិនិត្យសំនួរ ២៥៦ :****អាហារដែលកូនបានបរិភោគ*

សំនួរនេះ ត្រួតពិនិត្យសំនួរ២៥៦ ដើម្បីកំនត់យ៉ាងតិចចំលើយមួយ "ចាស់" ដែលបានគូសរង្វង់សំរាប់អាហារនិមួយៗ គឺមានន័យថា កូនគាត់បានហូបអាហារមួយចំនួនក្នុងកំឡុងពេលថ្ងៃ ឬពេលយប់ដែលបានសំភាសន៏។

***សំនួរ ២៥៧:*** *ចំនួនដងនៃការផ្តល់អាហារអោយកូនក្រៅពីវត្ថុរាវ*

ក្នុងសំនួរនេះ យើងព្យាយាមកំនត់ចំនួនដងសរុបនៃការផ្តល់អាហារអោយកូនក្រៅពីវត្ថុរាវ នៅមុន១ថ្ងៃនៃការសំភាសន៏។ ចូររៀបរាប់ដោយឡែកពីគ្នានូវចំនួនអាហារសំរន់ ដែលគាត់បានផ្តល់អោយកូននៅចន្លោះពេលអាហារជាប្រចាំ។ បើចំនួនដងចាប់ពី៧ដងឡើងទៅ ត្រូវកត់ត្រា លេខ៧ ក្នុងប្រអប់។

***សំនួរ ២៥៨:*** *វត្ថុរាវ និង អាហារដែលស្ត្រីបានហូបកាលពីម្សិលម៉ិញ*

គោលបំណងនៃសំនួរនេះ គឺដើម្បីបញ្ជាក់ពីប្រភេទនៃវត្ថុរាវ និងអាហារច្បាស់លាស់ ដែលស្ត្រីបានហូបកាលពីម្សិលមិញ(ក្នុងរយះពេល២៤ម៉ោងមុនការសំភាសន៏)។

***សំនួរ ២៥៩:*** *ចំនួនដងនៃអាហារដែលស្ត្រីបានបរិភោគក្រៅពីវត្ថុរាវ*

ក្នុងសំនួរនេះ យើងព្យាយាមកំនត់ចំនួនដងសរុបនៃការហូបអាហាររបស់ស្ត្រីក្រៅពីវត្ថុរាវ នៅមុន១ថ្ងៃនៃការសំភាសន៏។ ចូររៀបរាប់ដោយឡែកពីគ្នានូវចំនួនអាហារសំរន់ដែលគាត់បានហូប នៅចន្លោះពេលអាហារជាប្រចាំ។ បើចំនួនដងចាប់ពី៧ដងឡើងទៅ ត្រូវកត់ត្រាលេខ៧ ក្នុងប្រអប់។